# តើជម្ងឺអ៊ុតស្វា គឺជាអ្វី?

ជម្ងឺអ៊ុតស្វា (MPX) គឺជាជំងឺមេរោគមួយដែលកំពុងរីកដុះដាលនៅក្នុងរដ្ឋកាលីហ្វ័រញ៉ា និងសហរដ្ឋអាមេរិក ចាប់តាំងពី និទាឃរដូវឆ្នាំ 2022។ ថ្វីបើហានិភ័យបច្ចុប្បន្នចំពោះសាធារណៈទូទៅមានកម្រិតទាបក្តីបុគ្គលណាម្នាក់ក៏អាចកើតមាន MPX។ វាជាការល្អក្នុងការដឹងពីសញ្ញា និងរោគសញ្ញា ដើម្បីរក្សាអ្នក និងអ្នកដទៃឲ្យមានសុវត្ថិភាព។

## តើវាឆ្លងដូចម្តេចដែរ?

### ការប៉ះ

ស្បែកទល់នឹងស្បែក (ការឱប ការថើប សកម្មភាពរួមភេទ) ជាមួយនរណាម្នាក់ដែលមានរោគសញ្ញា។

### ចែករំលែករបស់របរ

ចែករំលែករបស់របរ (សម្លៀកបំពាក់ គ្រឿងពូក កន្សែង) ប្រើដោយអ្នកដែលមានរោគសញ្ញា។

MPX អាចឆ្លងតាមរយៈអន្តរកម្មជិតស្និទ្ធពីការនិយាយ ការក្អក និងការដកដង្ហើមនៅជិតនរណាម្នាក់ក្នុងរយៈពេលយូរ។ រឿងនេះកើតឡើងជាចម្បងនៅពេលរស់នៅជាមួយ ឬថែទាំអ្នកដែលមានរោគសញ្ញា។

## តើមានរោគសញ្ញាអ្វីខ្លះ?

រោគថើស្បែកដែលអាចមើលទៅដូចជាមុន ឬពងបែកដែលលេចឡើងនៅលើមុខ ខាងក្នុងមាត់ និងនៅលើផ្នែកផ្សេងទៀតនៃរាងកាយ ដូចជាដៃ ជើង ទ្រូង ប្រដាប់ភេទ និងរន្ធគូថ។

### រោគសញ្ញាដទៃទៀត

- គ្រុន
- ការឈឺខ្លួន
- ការហើមកូនកណ្តុរ
- ឈឺក្បាល
- រងាញាក់
- អស់កម្លាំង

## តើយើងអាចទប់ស្កាត់វាដូចម្តេច?

- ជៀសវាងការទំនាក់ទំនងជិតស្និទ្ធ រួមទាំងទំនាក់ទំនងផ្លូវភេទជាមួយអ្នកឈឺ ឬមានរោគថើស្បែក។
- ជៀសវាងការចែករំលែកគ្រែ កន្សែង សំលៀកបំពាក់ ពែង និងប្រដាប់ប្រដាប្រើប្រាស់ជាមួយអ្នកដែលមានរោគសញ្ញា។ របស់របរត្រូវតែយកសំអាតនិងសម្លាប់មេរោគ មុននឹងយកមកប្រើដោយអ្នកដទៃ។

## តើអ្នកគួរធ្វើដូចម្តេចប្រសិនបើអ្នកមានរោគសញ្ញា?

- ទំនាក់ទំនងអ្នកផ្តល់សេវាថែទាំសុខភាពមួយរំពេច។
- នៅផ្ទះឱ្យនៅដាច់ដោយឡែករហូតដល់កន្ទួលរមាស់ ស្នាមបានជ្រុះ ហើយស្រទាប់ស្បែកថ្មីបានបង្កើតឡើង។
- ប្រសិនបើអ្នកមានកន្ទួលសកម្ម ឬរោគសញ្ញាផ្សេងទៀត សូមស្នាក់នៅបន្ទប់ដាច់ដោយឡែក ឬកន្លែងឆ្ងាយពីមនុស្ស ឬសត្វចិញ្ចឹមដែលអ្នករស់នៅ។ ប្រសិនបើអ្នកត្រូវការនៅក្បែរអ្នកដ៏ទៃនៅក្នុងផ្ទះរបស់អ្នក (ឧ. ថែទាំកុមារ ឬសមាជិកគ្រួសារ) បិទបាំងដំបៅ/កន្ទួល ហើយពាក់ម៉ាស។

នៅពេលដែលអាចធ្វើទៅបាន អ្នកដែលមាន MPX គួរតែផ្លាស់ប្តូរបង់រុំផ្ទាល់ខ្លួនរបស់ពួកគេ និងដោះស្រាយក្រណាត់របស់ពួកគេខណៈពេលដែលពាក់ស្រោមដៃដែលអាចចោលបាន បន្ទាប់មកដោយការលាងដៃភ្លាមៗបន្ទាប់ពីដោះស្រោមដៃចេញ។

**រោគសញ្ញាអាចចាប់ផ្តើមនៅកន្លែងណាមួយចាប់ពី 5-21 ថ្ងៃបន្ទាប់ពីការប៉ះពាល់។**

## តើមានការព្យាបាលឬវ៉ាក់សាំងឬទេ?

**ការព្យាបាល៖ បុគ្គលជាច្រើនរូបនឹងមានរោគសញ្ញាស្រាលហើយមិនត្រូវការការព្យាបាលទេ។ អ្នកផ្តល់ការថែទាំអាចណែនាំប្រាប់អំពីការព្យាបាលដើម្បីកាត់បន្ថយរោគសញ្ញារបស់អ្នក។**

**វ៉ាក់សាំង៖ មនុស្សដែលសមស្របនឹងលក្ខណៈវិនិច្ឆ័យនៃការប៉ះពាល់ និងហានិភ័យជាក់លាក់អាចមានសិទ្ធិទទួលបានវ៉ាក់សាំង។**

**ទាក់ទងអ្នកផ្តល់សេវាសុខភាពឬ ក្រសួងសុខាភិបាលមូលដ្ឋានរបស់អ្នកជាមួយនឹងសំណួរ។**

GO.CDPH.CA.GOV/MONKEYPOX

Monkeypox • Khmer • August 2022 © California Department of Public Health